01212444

**Declassified to Public**
**28 June 2019**

លេខ៖ 9302

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 07 / 03 / 2016
ម៉ោង (Time/Heure) : 12:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**
កាលបរិច្ឆេទ ៖ **ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦**
ភាសា ៖ **ខ្មែរ/អង់គ្លេស**
ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# សំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តីអោ អាន**
មុំ លុច
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តីអ៊ឹម ចែម**
ប៊ិត សៀងលីម
John R.W.D. Jones

**មេធាវីការពារក្តីយឹម ទិត្យ**
សូ មូស្សេនី
Suzana TOMANOVIĆ

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉េន ពៅ
Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ យឹម ទិត្យ បានចូលបង្ហាញខ្លួនលើកដំបូង អនុលោមតាមវិធាន ផ្ទៃក្នុង ៥៧ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”)។

២. នៅក្នុងអំឡុងពេលសវនាការបង្ហាញខ្លួននេះ ខ្ញុំបានជូនដំណឹង យឹម ទិត្យ ថាខ្ញុំកំពុងពិចារណា មិនស៊ើបអង្កេតថែមទៀតលើអង្គហេតុមួយចំនួនដែលបានចោទនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿង ឲ្យស៊ើបសួរលើកទី៣[1] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម នានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើប សួរបន្ថែមទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ[3] និងដីកាសន្និដ្ឋាន បញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយ បង្ខំនៅក្នុងតំបន់១ និងតំបន់ ៤ (“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទី៤”)[4] (តទៅនេះ ហៅរួមថា “ដីកាសន្និដ្ឋាន”)ចេញពីការិយាល័យសហព្រះរាជអាជ្ញា (“ក.ស.ព”) ហើយខ្ញុំនឹង ស្នើភាគីទាំងអស់ ឲ្យបង្ហាញមតិយោបល់អំពីបញ្ហានេះ។ អង្គហេតុទាំងនេះគឺសំដៅលើ អង្គហេតុទី ១ ដល់ អង្គហេតុទី ១៣ មានដូចខាងក្រោម។

## II. ពិភាក្សា

៣. ទាក់ទងនឹងអង្គហេតុខាងក្រោមនេះដែលបានចោទនៅក្នុងដីកាសន្និដ្ឋាន ខ្ញុំមានបំណងមិនស៊ើប អង្កេតថែមទៀតទេ៖

---

[1] សំណុំរឿង00៤ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២00៨។

[2] សំណុំរឿង00៤ ឯកសារ D65 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១(“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទី ១”)។

[3] សំណុំរឿង00៤ ឯកសារ D191 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤(“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទី ២”)។

[4] សំណុំរឿង00៤ *ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ ដោយបង្ខំនៅតំបន់ ១ និងតំបន់ ៤* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥(“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទី ៤”)។

- **អង្គហេតុទី ១**[5]- ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងមន្ទីរសន្តិសុខវត្តសុបិន នៅស្រុកគិរីវង់ តំបន់ ១៣ ភូមិភាគនិរតី យោងតាមរចនាសម្ព័ន្ធរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យ[6]៖

  ការចោទប្រកាន់របស់ ក.ស.ព ពាក់ព័ន្ធតែឧក្រិដ្ឋកម្មដែលបានចោទថាបានប្រព្រឹត្តឡើងមកលើខ្មែរក្រោម។ ប៉ុន្តែ មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ខ្មែរក្រោម ត្រូវបានសម្លាប់ឲ្យបានច្បាស់លាស់ និងកប់នៅមន្ទីរសន្តិសុខវត្តសុបិននៅឆ្នាំ ១៩៧៦ និង ១៩៧៧ ទេ។

- **អង្គហេតុទី ២** - ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងភូមិសោម នៅស្រុកគិរីវង់ តំបន់ ១៣ ភូមិភាគនិរតី[7]៖

  ការចោទប្រកាន់ទាំងនេះពាក់ព័ន្ធតែឧក្រិដ្ឋកម្មដែលបានចោទថាបានប្រព្រឹត្តឡើងមកលើខ្មែរក្រោម។ ប៉ុន្តែ មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ខ្មែរក្រោម ត្រូវបានសម្លាប់នៅភូមិសោមទេ។

- **អង្គហេតុទី ៣** -ការចោទប្រកាន់ទាក់ទងនឹងការដាក់គោលដៅលើក្រុមខ្មែរក្រោម និងវៀតណាមនៅសហករណ៍ធិបតី ស្រុកគាស់ក្រឡ តំបន់ ១ ភូមិភាគពាយ័ព្យ[8]៖

  មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ខ្មែរក្រោម និងជនជាតិវៀតណាម ត្រូវបានដាក់ជាក្រុមគោលដៅ ត្រូវបានចាប់ខ្លួន និងសម្លាប់ឲ្យបានច្បាស់លាស់ទេ។

- **អង្គហេតុទី ៤**-ការចោទប្រកាន់ទាក់ទងនឹងមន្ទីរសន្តិសុខវត្តបន្ទាយត្រែង នៅស្រុករតនៈមណ្ឌល តំបន់ ១ ភូមិភាគពាយ័ព្យ[9]៖

  កិច្ចស៊ើបសួរដើម្បីស្វែងរកអត្តសញ្ញាណសាក្សី និងភស្តុតាង មិនបានទទួលជោគជ័យ ។ មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីការចោទប្រកាន់របស់ ក.ស.ព ទេ។

---

[5]គួរកត់សម្គាល់ថា ការចោទប្រកាន់ទាំងអស់គឺសំដៅលើអង្គហេតុមួយ។

[6]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទី ១ កថាខណ្ឌ ១២។

[7]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទី ១ កថាខណ្ឌ ១២។

[8]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទី ២ កថាខណ្ឌ ៨។

[9]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ៣ កថាខណ្ឌ ៦២។

- **អង្គហេតុទី ៥**-ការចោទប្រកាន់អំពីការសម្លាប់រួមនៅភ្នំត្រដាក់ចិត្ត តំបន់ ១ ភូមិភាគពាយ័ព្យ[10]៖
ភស្តុតាងបង្ហាញថា ការសម្លាប់ដែលបានធ្វើឡើងគឺស្ថិតនៅក្រៅយុត្តាធិការពេលវេលារបស់ អ.វ.ត.ក យោងតាមមាត្រា ១។

- **អង្គហេតុទី ៦**-ការចោទប្រកាន់ទាក់ទងនឹងទីតាំងសម្លាប់មនុស្សអំណាក់វាំង នៅជិតប៉ៃលិន យោងតាមដីកាសន្និដ្ឋានរបស់ ក.ស.ព[11]៖
ទីតាំងសម្លាប់មនុស្សដែលបានចោទនេះមិនអាចរកឃើញទេ[12]។ មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីការចោទប្រកាន់របស់ ក.ស.ព ទេ។

- **អង្គហេតុទី ៧**-ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងគុកត្រាចក្រោល ហៅ គុកបឹងបាតកណ្ដាល នៅស្រុកបាកាន តំបន់ ២ ភូមិភាគពាយ័ព្យ[13]៖
ការចោទប្រកាន់ទាំងនេះពាក់ព័ន្ធតែឧក្រិដ្ឋកម្មដែលបានចោទថាបានប្រព្រឹត្តឡើងមកលើខ្មែរក្រោម។ ប៉ុន្តែ មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ខ្មែរក្រោមត្រូវបានចាប់ខ្លួន និងជាប់ឃុំនៅមន្ទីរសន្តិសុខនេះឲ្យបានច្បាស់លាស់ទេ។

- **អង្គហេតុទី ៨**-ការចោទប្រកាន់ទាក់ទងនឹងល្អាងគួយឃំ នៅស្រុកមង្គលបូរី តំបន់ ៣ ភូមិភាគពាយ័ព្យ[14]៖
ភស្តុតាងបង្ហាញថា ការសម្លាប់ដែលបានធ្វើឡើង គឺស្ថិតនៅក្រៅយុត្តាធិការពេលវេលារបស់ អ.វ.ត.ក យោងតាមមាត្រា ១។

- **អង្គហេតុទី ៩**-ការចោទប្រកាន់ទាក់ទងនឹងការដាក់គោលដៅលើជនជាតិវៀតណាម ការចាប់ខ្លួន និងការសម្លាប់ជនជាតិវៀតណាមនៅក្នុងឃុំវាំងកេសី ស្រុកសង្កែ តំបន់ ៤ ភូមិភាគពាយ័ព្យ[15]៖

---

[10]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទី ១ កថាខណ្ឌ ៧។

[11]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទី ១ កថាខណ្ឌ ៩។

[12]សំណុំរឿង ០០៤ ឯកសារ D105/21 *របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស* ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៤ និងសំណុំរឿង០០៤ ឯកសារ D118/121 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ ទំព័រ ២។

[13]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទី ១ កថាខណ្ឌ ១៦។

[14]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ៣ កថាខណ្ឌ ៧០។

[15]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទី ២ កថាខណ្ឌ ៨។

មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ជនជាតិវៀតណាម ត្រូវបានដាក់ជាគោលដៅ ត្រូវបានចាប់ខ្លួន និងសម្លាប់នៅទីតាំងនេះទេ។

- **អង្គហេតុទី** ១០- ការចោទប្រកាន់ទាក់ទងនឹងការរំលោភផ្លូវភេទ និងការសម្លាប់នារីពីរនាក់ដែលមានដើមកំណើតជាជនជាតិវៀតណាមនៅស្រុកព្រះនេត្រព្រះ តំបន់ ៥ ភូមិភាគពាយ័ព្យ[16]៖
  មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីការចោទប្រកាន់របស់ ក.ស.ព អំពីការរំលោភផ្លូវភេទ ទេ។

- **អង្គហេតុទី** ១១-ការចោទប្រកាន់អំពីអំពើហិង្សាផ្លូវភេទ រួមមានការរំលោភផ្លូវភេទ ហើយសម្លាប់នារីខ្មែរក្រោម និង "អ្នកជម្លៀសមកពីភូមិភាគបូព៌ា"នៅស្រុកបាកាន តំបន់ ២ ភូមិភាគពាយ័ព្យ[17]៖
  មានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា ការរំលោភផ្លូវភេទ ដែលជាអំពើអមនុស្សធម៌មួយទៀតយោងតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ប្រហែលជាបានប្រព្រឹត្តឡើងមកលើនារីខ្មែរក្រោម និង "អ្នកជម្លៀសមកពីភូមិភាគបូព៌ា"នៅស្រុកបាកាន ប៉ុន្តែ មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា យឹម ទិត្យ អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះទេ។

- **អង្គហេតុទី** ១២-ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ នៅស្រុកកណ្តៀង តំបន់ ៧ ភូមិភាគពាយ័ព្យ[18]៖
  មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា យឹម ទិត្យ អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះទេ។

- **អង្គហេតុទី** ១៣-នេះទាក់ទងនឹងការចោទប្រកាន់អំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅ"ភូមិក្របុក" នៅ "ឃុំបាណន់" នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី ៤[19]។ ប៉ុន្តែ មិនមានឈ្មោះភូមិក្របុក ទេ។ ហាក់ដូចជាថា មានឈ្មោះភូមិ

[16] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី ២ កថាខណ្ឌ ៩។

[17] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី ២ កថាខណ្ឌ ៧។

[18] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ កថាខណ្ឌ ៧៣។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី ១ កថាខណ្ឌ ១៨-១៩។

[19] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី ៤ កថាខណ្ឌ ៦។

នេះដោយសារកំហុសផ្នែកបកប្រែភាសា។ ប៉ុន្តែ ព្រឹត្តិការណ៍សំខាន់ៗត្រូវបានចោទថាបានកើតឡើងនៅជិតទំនប់ កង្កួត នៅស្រុកសង្កែ តំបន់ ១ ភូមិភាគពាយ័ព្យ[20]។ បច្ចុប្បន្ននេះ សាក្សីម្នាក់ដែលគួរឱ្យទុកចិត្តបាន បានផ្តល់ភស្តុតាងបញ្ជាក់ពីពិធីរៀបការដោយបង្ខំមួយនៅជិតទំនប់កង្កួត ដោយមាន ២០ គូរ ហើយមានអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ដែលប្រហែលជាអាចផ្តល់ព័ត៌មានអំពីពិធីរៀបការដោយបង្ខំនៅទីតាំងដដែលនេះ។ បច្ចុប្បន្ននេះ ខ្ញុំមិនមាននិន្នាការចង់បន្តការចោទប្រកាន់នេះទៀតទេ។

៤. យោងតាមខាងលើ បច្ចុប្បន្ននេះ ខ្ញុំមាននិន្នាការចង់ដកអង្គហេតុទី ១ ដល់ អង្គហេតុទី ១៣ ចេញពីកិច្ចស៊ើបសួរ។ ខ្ញុំក៏ជឿជាក់ថា កិច្ចស៊ើបសួរបន្ថែមទៀតនឹងមិនកែប្រែស្ថានភាពបច្ចុប្បន្ននេះទេ។

៥. ចំពោះបញ្ហាអង្គច្បាប់ អង្គហេតុដែលបានលើកឡើងខាងលើ ជាបឋម ហាក់ស្តែងឱ្យឃើញថាត្រូវលើកលែងការចោទប្រកាន់មួយចំនួន ក្រៅពីអង្គហេតុទី ១៣ ដែលអាចជាករណីមួយសម្រាប់អនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន*។ ប៉ុន្តែ មិនច្បាស់ថាអាចអនុវត្តវិធានផ្ទៃក្នុង ៦៦ *ស្ទួន* បានទេនៅក្នុងស្ថានភាពដែលលក្ខខណ្ឌផ្សេងទៀតទាំងអស់នៃវិធាននេះត្រូវបានបំពេញ ប៉ុន្តែមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់។ បន្ថែមពីលើនេះទៀត វិធាននេះមិនទាន់ធ្លាប់បានអនុវត្តទេរហូតដល់សព្វថ្ងៃនេះ ដូច្នេះ មិនមានយុត្តិសាស្ត្រដើម្បីជាពន្លឺសម្រាប់បញ្ហាចោទនេះទេ។ ហេតុនេះ ខ្ញុំសូមស្វាគមន៍មតិយោបល់ពីភាគីទាំងអស់ ស្តីពីការបកស្រាយវិធានផ្ទៃក្នុង ៦៦*ស្ទួន* នៅក្នុងបរិបទនេះ។

៦. ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេសដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

**តាមសំអាងហេតុខាងលើ ខ្ញុំៈ**

៧. **ជូនដំណឹង** ភាគីទាំងអស់ថា បច្ចុប្បន្ននេះ ខ្ញុំមាននិន្នាការចង់ដកអង្គហេតុទី ១ ដល់ អង្គហេតុទី ១៣ ចេញពីកិច្ចស៊ើបសួរ។

---

[20]ឯកសារ D219/647 កំណត់ហេតុនៃកិច្ចស៊ើបសួរ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦។

01212450

០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស លេខ៖ D302

៨. **ជូនដំណឹង** ភាគីទាំងអស់ថា កថាខណ្ឌ ៦(ខ)នៅក្នុងចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយបង្ខំនៅតំបន់ ១ និងតំបន់ ៤ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ គឺពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅជិតទំនប់កង្កួត ស្រុកសង្កែ តំបន់ ១ ភូមិភាគពាយ័ព្យ។

៩. **ស្នើ** ការិយាល័យសហព្រះរាជអាជ្ញា ក្នុងរយៈពេលមួយខែចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងអំពីដីកាសម្រេចនេះ ត្រូវដាក់សេចក្តីកែតម្រូវចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយបង្ខំនៅតំបន់ ១ និងតំបន់ ៤ ដូចបានបង្ហាញនៅក្នុងកថាខណ្ឌខាងលើ។

១០. **ស្នើ** ភាគីទាំងអស់ ក្នុងរយៈពេលមួយខែចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងអំពីដីកាសម្រេចនេះ ត្រូវដាក់សារណា/សេចក្តីសន្និដ្ឋានដែលខ្លួនអាចមានស្តីពីបញ្ហាខាងលើ ជាពិសេស ថាតើខ្លួនពិចារណាលើកលែងការចោទប្រកាន់ដែរឬអត់ចំពោះអង្គហេតុទី ១ ដល់អង្គហេតុទី ១៣ យោងតាមវិធានផ្ទៃក្នុង ៦៧ និង/ឬថាតើខ្លួនយល់ឃើញថា ការអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន* គឺជាត្រឹមត្រូវដែរឬអត់។

១១. **ជូនដំណឹង** ភាគីទាំងអស់ថា ការឆ្លើយតប និងចម្លើយតបទៅនឹងសារណា/សេចក្តីសន្និដ្ឋានរបស់ភាគីផ្សេង មិនត្រូវបានអនុញ្ញាតទេនៅពេលនេះ។

ភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦

ចៅក្រម Michael Bohlander

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**